**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

** **

**សាលាដំបូងខេត្តសៀមរាប**
**<u>សាលក្រមព្រហ្មទណ្ឌលេខៈ</u>** ១១៨ (ឈ)
ចុះថ្ងៃទី៣០ ខែ០៧ ឆ្នាំ២០២០
**<u>សំណុំរឿងព្រហ្មទណ្ឌលេខៈ២៣៨</u>**
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០
**<u>សំណុំរឿងជំនុំជម្រះលេខៈ៨០៦</u>**
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**<u>សាលាដំបូងខេត្តសៀមរាប</u>**

ដែលបានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប
-បើកសវនាការថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២:៣០ នាទីរសៀល ។
-ប្រកាសសាលក្រមនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ម៉ោង៩:០០ នាទីព្រឹក ។

<u>ដោយមានសមាសភាពដូចខាងក្រោមៈ</u>

<u>ចៅក្រមជំនុំជម្រះ</u>

លោក [redacted] ជាចៅក្រមជំនុំជម្រះ

<u>តំណាងអយ្យការ</u>

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

**<u>ដើម្បីជំនុំជម្រះ</u>** រឿងក្ដីព្រហ្មទណ្ឌលេខ៖ ២៣៨ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

ក. ឈ្មោះ [redacted] ឡោត ភេទប្រុស អាយុ ៤៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូ [redacted] ខេត្តសៀមរាប មុខរបរលក់នំ ប្រពន្ធឈ្មោះ [redacted] អៃ ឪពុកឈ្មោះ [redacted] កោរ " វ " ម្ដាយឈ្មោះ [redacted] នុំ "ស" ។ ( ដីកាបង្គាប់ឱ្យដោះលែងលេខ ២៩០៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ )

**ជាប់ចោទពីបទ: បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៥** នៃ**ច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង** ។

- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ

**រឿងហេតុ មានដូចតទៅ:**

កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្ថិតនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កម្លាំងកងរាជអាវុធហត្ថខេត្តសៀមរាប បានបង្ក្រាបករណីលេងល្បែងស៊ីសងខុសច្បាប់ (លេងអាប៉ោង) បានឃាត់ខ្លួនឈ្មោះ [redacted] ឡោត ភេទប្រុស អាយុ ៤៨ឆ្នាំ ដកហូតសម្ភារៈមាន បៀ គ្រាប់ខ្លាឃ្លោក គ្រាប់អាប៉ោង ចានក្រឡុកខ្លាឃ្លោក និងអាប៉ោង កម្រាលខ្លាឃ្លោក និងអាប៉ោង រួចកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខដីកាសន្និដ្ឋានស្ថាពរលេខ៖ ៤៧២ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការ-អមសាលាដំបូងខេត្តសៀមរាប។

Scanned with CamScanner

-បានឃើញដីកាដំណោះស្រាយលេខ៖៣៥៦៧/២០២០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលា- ដំបូងខេត្តសៀមរាប។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖១២៧៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ របស់ប្រធានសាលា-ដំបូងខេត្តសៀមរាប។

## ពេលសវនាការ

## ក្រោយពីបានៈ

-ស្តាប់ចម្លើយជនជាប់ចោទ

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ ។

## សំអាងហេតុ

១-លទ្ធផលនៃកិច្ចពិភាក្សាដេញដោលពិនិត្យភស្តុតាង នាពេលសវនាការ និងយោងតាមរបាយការណ៍ស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ បង្ហាញឲ្យឃើញថាពិតជាមានអំពើ " **បើកអកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** " ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ប្រាកដមែន។

២-ភស្តុតាងដាក់បន្ទុកមាន:

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឡោត បានឆ្លើយថា ៖ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅវេលាម៉ោង ២ រសៀល ខណៈអ្នកភូមិមានគ្នាប្រហែលជា ២០នាក់កំពុងលេងអាប៉ោងនៅលើដីរបស់ឈ្មោះ [redacted] អាយុ ប្រហែល ៨៤ឆ្នាំ ជាប្រជាការពារភូមិថ្មី មានប្រពន្ធឈ្មោះ ហេង ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនតែម្តង ។ ការលេងបាញ់អាប៉ោងនេះខ្លួន បានលេងមិនបានលេងភ្នាល់លុយធំដុំអ្វីនោះទេគឺម្នាក់លេងភ្នាល់ពី២,០០០ រៀល ទៅ៣,០០០ រៀល ចំណែកខ្លួនមិនបានចូលរួមលេង និងគេនោះទេ គឺគ្រាន់តែផ្តល់ទីតាំងតែប៉ុណ្ណោះដោយក្នុងមួយថ្ងៃគេឱ្យកម្រៃខ្លួនពី២០,០០០ រៀល ទៅ ៣០,០០០ រៀល។ ខ្លួនទើបតែអនុញ្ញាតឱ្យគេលេងភ្នាល់ល្បែងអាប៉ោងនេះ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ហើយគេមកលេងរាល់ថ្ងៃរហូតដល់ថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននេះ ហើយមូលហេតុដែលខ្លួនអនុញ្ញាតឱ្យគេលេងល្បែងដើម្បីយកកម្រៃនេះ គឺដោយសារខ្លួនមានជីវ ភាពខ្វះខាត ម្យ៉ាងទៀតខ្លួនពិការជើងពុំអាចធ្វើការងារអ្វីបាន ។ ការលេងភ្នាល់ល្បែងអាប៉ោងនេះ មិនមែនលេងនៅលើដីរបស់ខ្លួននោះទេ គឺលេងនៅលើដីរបស់ឈ្មោះ ស៊ត មានប្រពន្ធឈ្មោះ ហេង រស់នៅភូមិថ្មី សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ទល់មុខផ្ទះរបស់ខ្លួនដោយខ្លួនសុំពួកគាត់ឱ្យគេលេង ហើយខ្លួនជាអ្នកទទួលកម្រៃ ។

៣-មានភស្តុតាងគ្រប់គ្រាន់កំណត់ពិរុទ្ធភាព : លើជនជាប់ចោទឈ្មោះ [redacted] ឡោត ពីបទ "**បើកអកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** " ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៥** នៃ**ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសងខុសច្បាប់** ។

៤-អំពីការប្រកាសទោស : គប្បីតុលាការប្រកាសទោសដាក់ពន្ធនាគារ ដល់ជនជាប់ចោទលើកម្រិតអប្បបរមានៃទោសដោយហេតុថារកពុំឃើញនូវលក្ខខណ្ឌណាមួយដែលគួរគ្រាប្រណីទោសដល់ជនជាប់ចោទឡើយ។

៥-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ:បានស្នើសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនដោយក្តីអនុគ្រោះ ។

Scanned with CamScanner

៦-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ: នាពេលសវនាការតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឲ្យតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ **៣៥៦៧** ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ទុកនៅទាំងស្រុង ។

តុលាការយល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១/-**ផ្តន្ទាទោស**: ឈ្មោះ [redacted] ឡោត ភេទប្រុស អាយុ ៤៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តសៀមរាប មុខរបរលក់នំ ប្រពន្ធឈ្មោះ [redacted] អៃ ឪពុកឈ្មោះ [redacted] កោរ " រ " ម្តាយឈ្មោះ [redacted] នុំ "ស" ។ ( ដីកាបង្គាប់ឲ្យដោះលែងលេខ ២៩០៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ )

**ដាក់ពន្ធនាគារ** កំណត់ ០១ ( មួយ ) ឆ្នាំ ។

ពីបទ: **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ស្វាយ ដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៥** នៃ **ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង** ។

២/-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទឈ្មោះ អេង ឡោត ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជី
ហត្ថលេខានិងត្រា
[redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខានិងត្រា
[redacted]

---

បានឃើញ
ចៅក្រមជំនុំជម្រះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
សៀមរាប, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃទី..១៣..... ខែ..សីហា...ឆ្នាំ២០២២
ក្រឡាបញ្ជី
[redacted]